# អនុក្រឹត្យ លេខ ៨៤ អនក្រ.បក
## ស្តីពី ដើមទុនធនាគារជាតិនៃកម្ពុជា

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

-តាមសំណើទេសាភិបាលធនាគារជាតិនៃកម្ពុជា

### សំរេច

**មាត្រា ១ .-** កំណត់ដើមទុនរបស់ធនាគារជាតិនៃកម្ពុជា ចំនួន ១០០.០០០.០០០.០០០.០០រៀល (មួយរយពាន់លានរៀល) ។

**មាត្រា ២ .-**

ធនាគារជាតិនៃកម្ពុជា ត្រូវចាត់ចែងការចុះបញ្ជីកា ក្នុងតារាងតុល្យការរបស់ខ្លួនអោយបានគ្រប់ចំនួន ។

**មាត្រា ៣ .-**

ដើមទុនខាងលើនេះត្រូវបានចុះបញ្ជី និងកាន់កាប់ផ្តាច់មុខដោយរាជរដ្ឋាភិបាល និងមិនអាចផ្ទេរ ឬដាក់អោយជាប់ល័ក្ខខ័ណ្ឌអ្វីឡើយ ។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០២ ខែ តុលា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

ទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ជា ចាន់តូ